ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ...០៤៥ សស.សក.../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី...២៨... ខែ...វិច្ឆិកា... ឆ្នាំ២០១៣

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឲ្យប្រើប្រាស់នូវសេចក្តីណែនាំស្តីពីកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុងស្រុកខណ្ឌ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៣ មាត្រា១៥ មាត្រា១៦ និងមាត្រា១៧ នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ



មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១/ ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www .ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ៣៦អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្ដីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងកិច្ចប្រជុំលើកទី៨ នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣។

## សម្រេច

**ប្រការ ១.–**

ដាក់ឲ្យប្រើប្រាស់នូវ " **សេចក្ដីណែនាំស្ដីពីកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់** "។

**ប្រការ ២.–**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវប្រើប្រាស់សេចក្ដីណែនាំនេះធ្វើជាមូលដ្ឋានក្នុងការពិនិត្យមើលមុខងារឡើងវិញរបស់ខ្លួន ដូចបានកំណត់ក្នុងអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្ដីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ៣.–**

សេចក្ដីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ជ.គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ**
**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**
**ប្រធាន**

ស ខេង

**ចម្លងជូនៈ**

- *ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*

*"ដើម្បីអនុវត្ត"*

- *ឯកសារ កាលប្បវត្តិ*

រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សេចក្តីណែនាំ
# ស្តីពី
# កិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ
# របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរ
# គ្រប់លំដាប់ថ្នាក់

ខែឧសភា ឆ្នាំ២០១៣

# មាតិកា


ទំព័រ

| | | | |
|---|---|---|---|
| I. | សេចក្តីផ្តើម | | ១ |
| II. | គោលបំណងនៃសេចក្តីណែនាំ | | ២ |
| III. | វិសាលភាពនៃសេចក្តីណែនាំ | | ២ |
| IV. | ដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ | | ២ |
| **ជំហានទី១** | : | ការរៀបចំ និងឯកភាពលើផែនការការងារនៃការពិនិត្យមើលមុខងារឡើងវិញ | ៤ |
| **ជំហានទី២** | : | ការកំណត់មុខងារនានាដែលត្រូវស្នើឡើងសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | ៦ |
| **ជំហានទី៣** | : | ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ | ១៥ |
| **ជំហានទី៤** | : | ការកំណត់នូវធនធាននានា ដែលត្រូវប្រើប្រាស់ដើម្បីអនុវត្តមុខងារដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរ | ១៨ |
| **ជំហានទី៥** | : | ការរៀបចំវិធីសាស្ត្រសម្រាប់ការផ្ទេរមុខងារនិងធនធានដែលត្រូវបានស្នើឡើង | ២០ |
| **ជំហានទី៦** | : | ការពិគ្រោះយោបល់ និងប្រមូលព័ត៌មាននៅថ្នាក់ក្រោមជាតិ | ២៣ |
| **ជំហានទី៧** | : | ការរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ | ២៧ |
| **ជំហានទី៨** | : | ការរៀបចំការពិគ្រោះយោបល់ដើម្បីបញ្ចប់របាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ និងផ្ញើរបាយការណ៍ជូន គ.ជ.អ.ប. | ២៩ |
| **ឧបសម្ព័ន្ធ** | : | ១. អ្នកពាក់ព័ន្ធនានាក្នុងដំណើរការពិនិត្យមុខងារឡើងវិញ | ៣០ |
| | | ២. ការពិចារណាបន្ថែមដើម្បីកំណត់អំពីកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការផ្ទេរ | ៣២ |

# សេចក្តីណែនាំស្តីពី
# កិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ
# របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់

## I. សេចក្តីផ្តើម

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកិច្ចដំណើរការនៃកំណែទម្រង់របស់រាជរដ្ឋាភិបាលក្នុងគោលដៅជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ លើកកម្ពស់ការអភិវឌ្ឍមូលដ្ឋានតាមរយៈការបង្កិតសេវាឱ្យទៅកៀកជិតប្រជាពលរដ្ឋ ក្នុងន័យកែលំអគុណភាពសេវា ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ និងអភិបាលកិច្ចមូលដ្ឋាន។

ដើម្បីសម្រេចបានគោលដៅខាងលើនេះ បណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ចាំបាច់ត្រូវធ្វើការផ្ទេរជាបណ្តើរៗឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនូវមុខងារជាក់លាក់របស់ខ្លួន រួមនឹងធនធាននានាដូចជាធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្សសម្រាប់អនុវត្តនូវមុខងារទាំងនោះផងដែរ។

នីតិវិធីនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិមានកំណត់នៅក្នុងអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុក្រឹត្យនេះតម្រូវឱ្យ គ.ជ.អ.ប. ដាក់ចេញនូវសេចក្តីណែនាំចំនួនពីរសម្រាប់គាំទ្រដល់ដំណើរការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិគឺ ១).សេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និង ២).សេចក្តីណែនាំស្តីពីកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។ សេចក្តីណែនាំទី១ ត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ដោយ គ.ជ.អ.ប. នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ សម្រាប់ជាមូលដ្ឋានក្នុងរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។ ផ្អែកលើសេចក្តីណែនាំនេះ ក្រសួង ស្ថាប័នមួយចំនួនបានរៀបចំបញ្ចប់នូវរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន និងបានបញ្ជូនមក គ.ជ.អ.ប. ដើម្បីពិនិត្យ និងសម្រេច។

ក្នុងដំណាក់កាលបន្ទាប់ ដើម្បីផ្តល់គោលការណ៍ណែនាំដល់ក្រសួង ស្ថាប័នក្នុងការរៀបចំកិច្ចដំណើរការពិនិត្យមើលមុខងារឡើងវិញដែលបានកំណត់នៅក្នុងរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារ និងធនធានរបស់ក្រសួង ស្ថាប័ននីមួយៗ គ.ជ.អ.ប. បានរៀបចំ និងដាក់ចេញនូវសេចក្តីណែនាំស្តីពីកិច្ចដំណើរការពិនិត្យមើលមុខងារឡើងវិញដែលកំណត់អំពីដំណើរការជាជំហានៗ ដើម្បីចងក្រងនូវព័ត៌មានចាំបាច់សម្រាប់រៀបចំរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់

លំដាប់ថ្នាក់ ។

របាយការណ៍ស្តីពីកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ននឹងក្លាយទៅជាមូលដ្ឋានដ៏រឹងមាំសម្រាប់ពិចារណាអំពីមុខងារ និងធនធាននានាដែលត្រូវផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិជាដំណាក់កាល មានសនិទានភាព លក្ខណៈជាប្រព័ន្ធ ការសម្របសម្រួល ការពិគ្រោះយោបល់ មានផែនការ មានតម្លាភាព និងប្រកបដោយសមធម៌ ។

លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុចាំបាច់នានាដល់ក្រសួង ស្ថាប័នក្នុងកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញនេះ ក្នុងករណីដែលមានសំណើសុំការគាំទ្រពីក្រសួង ស្ថាប័នណាមួយ ។

## II. គោលបំណង

សេចក្តីណែនាំនេះត្រូវបានរៀបចំឡើងសម្រាប់ណែនាំដល់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការរៀបចំកិច្ចដំណើរការនៃការពិនិត្យមើលមុខងាររបស់ខ្លួនឡើងវិញ ដើម្បីកំណត់នូវមុខងារ និងធនធាននានាដែលត្រូវផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## III. វិសាលភាពនៃសេចក្តីណែនាំ

សេចក្តីណែនាំនេះផ្តោតតែទៅលើកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដោយផ្អែកលើរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័នដែលបានអនុម័តដោយ គ.ជ.អ.ប. ។

## IV. ដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវមានភាពជាម្ចាស់លើការពិនិត្យមើលមុខងាររបស់ខ្លួនឡើងវិញ និងត្រូវធានាឱ្យមានការចូលរួមពីអង្គភាពពាក់ព័ន្ធនានារបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ។ ចំពោះក្រសួង ស្ថាប័នដែលបាននិងកំពុងពិនិត្យមើលមុខងារឡើងវិញ ត្រូវពិនិត្យ និងកែសម្រួលឱ្យស្របតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ។

ក្នុងកិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវផ្អែកលើរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន ដែលត្រូវបានអនុម័តដោយ គ.ជ.អ.ប. និងត្រូវអនុវត្តទៅតាមជំហានសំខាន់ៗទាំង៨ដូចខាងក្រោម :

## ជំហានសំខាន់ៗសម្រាប់
## កិច្ចដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ
## របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់

**ជំហានទី១** : ការរៀបចំ និងឯកភាពលើផែនការការងារនៃការពិនិត្យមើលមុខងារឡើងវិញ

⇩

**ជំហានទី២** : ការកំណត់មុខងារនានាដែលត្រូវស្នើឡើងសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

⇩

**ជំហានទី៣** : ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

⇩

**ជំហានទី៤** : ការកំណត់នូវធនធាននានា ដែលត្រូវប្រើប្រាស់ដើម្បីអនុវត្តមុខងារដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរ

⇩

**ជំហានទី៥** : ការរៀបចំវិធីសាស្ត្រសម្រាប់ការផ្ទេរមុខងារ និងធនធានដែលត្រូវបានស្នើឡើង

⇩

**ជំហានទី៦** : ការពិគ្រោះយោបល់ និងប្រមូលព័ត៌មាននៅថ្នាក់ក្រោមជាតិ

⇩

**ជំហានទី៧** : ការរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ

⇩

**ជំហានទី៨** : ការរៀបចំការពិគ្រោះយោបល់ដើម្បីបញ្ចប់របាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ និងផ្ញើរបាយការណ៍ជូន គ.ជ.អ.ប.

# ជំហានទី១
# ការរៀបចំ និងឯកភាពលើផែនការការងារ
# នៃការពិនិត្យមើលមុខងារឡើងវិញ

## ក. គោលបំណង

គោលបំណងនៃជំហានទី១នេះ គឺដើម្បីឱ្យក្រសួង ស្ថាប័នរៀបចំ និងឯកភាពលើផែនការការងារ សម្រាប់ការអនុវត្តកិច្ចដំណើរការពិនិត្យមើលមុខងាររបស់ខ្លួនឡើងវិញស្របតាមជំហាន និងពេលវេលាដែលបានកំណត់ ។

## ខ.លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកក្នុងជំហាននេះ គឺការរៀបចំបាននូវផែនការការងារនៃការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន ។

តារាងគំរូទី១៖ ផែនការការងារនៃការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន .................

| លរ | ជំហាន | សកម្មភាពលម្អិត | អ្នកទទួលខុសត្រូវ | កាលបរិច្ឆេទចាប់ផ្ដើម និងបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | ការរៀបចំ និងឯកភាពលើផែនការការងារនៃការពិនិត្យមើលមុខងារឡើងវិញ | | | | |
| ២. | ការកំណត់មុខងារនានាដែលត្រូវស្នើឡើងសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ | | | | |
| ៣. | ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ | | | | |
| ៤. | ការកំណត់នូវធនធាននានា ដែលត្រូវប្រើប្រាស់ដើម្បីអនុវត្តមុខងារដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរ | | | | |
| ៥. | ការរៀបចំវិធីសាស្ត្រសម្រាប់ការផ្ទេរមុខងារដែលត្រូវបានស្នើឡើង | | | | |
| ៦. | ការពិគ្រោះយោបល់ និងប្រមូលព័ត៌មាននៅថ្នាក់ក្រោមជាតិ | | | | |
| ៧. | ការរៀបចំសេចក្ដីព្រាងរបាយការណ៍ស្ដីពីការពិនិត្យមើលមុខងារឡើងវិញ | | | | |
| ៨. | ការរៀបចំការពិគ្រោះយោបល់ដើម្បីបញ្ចប់របាយការណ៍ស្ដីពីការពិនិត្យមើលមុខងារឡើងវិញ និងផ្ញើរបាយការណ៍ជូន គ.ជ.អ.ប. | | | | |

## គ. ដំណើរការ

បន្ទាប់ពីទទួលបានការឯកភាពពី គ.ជ.អ.ប. លើរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារ ក្រសួង ស្ថាប័នត្រូវរៀបចំផែនការការងារសម្រាប់ដំណើរការនៃការពិនិត្យមើលមុខងារ និងធនធានរបស់ខ្លួនឡើងវិញ តាមសកម្មភាពសំខាន់ៗដូចតទៅ :

១. **ការរៀបចំកិច្ចប្រជុំផ្ទៃក្នុង** : ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័ន ត្រូវរាយការណ៍ដោយសង្ខេបជូនថ្នាក់ដឹកនាំរបស់ខ្លួនអំពីដំណើរការនៃការពិនិត្យមើលមុខងារឡើងវិញ ដែលក្នុងនោះរួមមានទាំងក្របខ័ណ្ឌគតិយុត្ត ក្របខ័ណ្ឌពេលវេលា ទម្រង់របាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ និងការគាំទ្រនានាពីលេខាធិការដ្ឋាន គ.ជ.អ.ប. ។

២. **ការកំណត់ពីតម្រូវការនៃជំនួយបច្ចេកទេស** : ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នត្រូវកំណត់អំពីតម្រូវការជំនួយបច្ចេកទេសដែលចាំបាច់ ដោយពិគ្រោះយោបល់ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ប្រសិនបើយល់ឃើញថា មានតម្រូវការបច្ចេកទេសដើម្បីអនុវត្តការពិនិត្យមើលមុខងារឡើងវិញ ។

៣. **ការរៀបចំសេចក្តីព្រាងផែនការការងារ** : ក្រុមការងារបច្ចេកទេសត្រូវកំណត់អំពីសកម្មភាពលម្អិត អ្នកទទួលខុសត្រូវ និងកាលបរិច្ឆេទនៃការចាប់ផ្តើម និងការបញ្ចប់ជំហាននីមួយៗនៃដំណើរការពិនិត្យមើលមុខងារឡើងវិញ ។ សេចក្តីព្រាងផែនការការងារនេះត្រូវរៀបចំដោយបញ្ចូលនូវកិច្ចការសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការកំណត់ផែនការសកម្មភាពជាក់លាក់សម្រាប់ការពិគ្រោះយោបល់ជាមួយអង្គភាពនានារបស់ក្រសួង ស្ថាប័នសាមី ការពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិ និងការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ។

៤. **ការពិនិត្យ និងឯកភាពលើផែនការការងារ** : បន្ទាប់ពីរៀបចំសេចក្តីព្រាងផែនការការងារខាងលើរួច ក្រុមការងារបច្ចេកទេសត្រូវបញ្ជូនសេចក្តីព្រាងនេះមកក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការដើម្បីពិនិត្យ និងដាក់ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នពិនិត្យ និងសម្រេច ។ បន្ទាប់ពីទទួលបានការឯកភាពពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ក្រុមការងារបច្ចេកទេសត្រូវធ្វើការផ្សព្វផ្សាយនូវផែនការការងារដល់អ្នកពាក់ព័ន្ធទាំងអស់ និងចាប់ផ្តើមអនុវត្តផែនការការងារនេះភ្លាម ។

៥. **ការជូនដំណឹងអំពីដំណើរការពិនិត្យមើលមុខងារឡើងវិញ** : ក្រសួង ស្ថាប័នគួរគប្បីពិចារណាអំពីការជូនដំណឹងដល់អង្គភាព និងមន្ត្រីក្រោមឱវាទនានាអំពីមូលហេតុដែលចាំបាច់តម្រូវឱ្យមានការពិនិត្យមើលមុខងារឡើងវិញ និងត្រូវបង្ហាញឱ្យបានច្បាស់ថា ដំណើរការនេះនឹងប្រព្រឹត្តទៅដោយតម្លាភាព ពុំធ្វើឱ្យបាត់បង់នូវអត្ថប្រយោជន៍ផ្សេងៗ និងអតីតភាពការងាររបស់មន្ត្រីទាំងនោះឡើយ ។

# ជំហានទី២
# ការកំណត់មុខងារនានាដែលត្រូវស្នើឡើងសម្រាប់ផ្ទេរ ឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ក. គោលបំណង

គោលបំណងនៃជំហានទី២នេះ គឺដើម្បីកំណត់អំពីមុខងារ និងឬមុខងាររងទាំងឡាយដែលត្រូវស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ខ. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកក្នុងជំហាននេះ គឺការបង្កើតបាននូវតារាងសំណើមុខងារ និងឬមុខងាររងដែលត្រូវពិនិត្យមើលឡើងវិញ (តារាងគំរូទី២) និងតារាងស្តីពីមុខងារ និងឬមុខងាររងដែលត្រូវបានស្នើឡើងសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិតាមកម្រិតថ្នាក់នីមួយៗ (តារាងគំរូទី៣) ។

## គ. ដំណើរការ

សកម្មភាពសំខាន់ៗដើម្បីអនុវត្តជំហានទី២ រួមមានដូចខាងក្រោម :

១. **ការកំណត់អំពីមុខងារ និងឬមុខងាររងដើម្បីស្នើឡើងសម្រាប់ការផ្ទេរ :** ក្រុមការងារបច្ចេកទេសត្រូវជ្រើសរើសយកមុខងារ និងឬមុខងាររងម្តងមួយៗ ពីតារាងបញ្ជីមុខងាររួម (តារាងទី៥) ដែលមាននៅក្នុងរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័នសាមីមកពិនិត្យមើលដោយផ្តោតជាពិសេសលើមុខងារ និងឬមុខងាររងដែលបានកំណត់ក្នុងក្របខ័ណ្ឌច្បាប់ និងត្រូវបានអនុវត្តជាក់ស្តែង ព្រមទាំងមានធនធានសម្រាប់អនុវត្តមុខងារ និងឬមុខងាររងនោះ។ ការពិនិត្យមើលមុខងារ និងឬមុខងាររងនីមួយៗសម្រាប់ស្នើឡើងក្នុងការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្អែកលើគោលការណ៍ដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ៦៨ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ដូចមានកំណត់ក្នុងតារាងខាងក្រោម)។ ក្រុមការងារបច្ចេកទេសអាចប្រើប្រាស់ផងដែរនូវបទពិសោធន៍ល្អៗពីការអនុវត្តកន្លងមកក្នុងប្រទេសកម្ពុជា និងបទពិសោធន៍របស់ប្រទេសដទៃដែលមានស្ថានភាពប្រហាក់ប្រហែលនឹងប្រទេសកម្ពុជាក្នុងការកំណត់អំពីមុខងារ និងឬមុខងាររងនេះ ។

| គោលការណ៍ | ចំណុចដែលត្រូវពិចារណា |
|---|---|
| ១.ស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ | • តើមុខងារ និងឬមុខងាររងនោះមានការពាក់ព័ន្ធ និងមានលក្ខណៈសមស្របនឹងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទណា ?<br>• មុខងារ និងឬមុខងាររងនោះបាននិងកំពុងអនុវត្តដោយមន្ទីរ ឬអង្គភាពជំនាញនៅថ្នាក់រាជធានី ខេត្ត ឬដោយការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុក ខណ្ឌ<br>• មុខងារ និងឬមុខងាររងដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនឹងមុខងារពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នផ្សេងទៀតដែលជួយធ្វើឱ្យការអនុវត្តនូវមុខងារ និងឬមុខងាររងនោះកាន់តែមានប្រសិទ្ធភាពក្នុងដែនសមត្ថកិច្ច របស់រដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ<br>• តើបុគ្គលិក និងទ្រព្យសម្បត្តិដែលមានបច្ចុប្បន្ន ហើយដែលពាក់ព័ន្ធនឹងមុខងារ និងឬមុខងាររងនេះស្ថិតនៅរដ្ឋបាលថ្នាក់ណា? |
| ២.អាចគ្រប់គ្រង និងអនុវត្តបានប្រកបដោយប្រសិទ្ធភាពនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ | • រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតទាបជាងគេបំផុតដែលអាចគ្រប់គ្រង និងអនុវត្តនូវមុខងារនេះប្រកបដោយប្រសិទ្ធភាព<br>• តើមានប្រសិទ្ធភាពចំណាយដែរឬទេ?<br>• តើមុខងារ និងឬមុខងាររងនោះអាចគ្រប់គ្រង និងអនុវត្តដោយក្រុមប្រឹក្សាតែមួយ ឬដោយក្រុមប្រឹក្សាពីរ ឬច្រើន ? |
| ៣.បម្រើ និងផ្តល់ផលប្រយោជន៍ចម្បងដល់ប្រជាពលរដ្ឋ | • តើមុខងារ ឬនិងមុខងាររងនោះ គឺជាតម្រូវការចាំបាច់ និងសំខាន់សម្រាប់ប្រជាពលរដ្ឋដែរឬទេ?<br>• តើប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ដែរឬទេ ហើយមានឆន្ទៈនឹងបង់ថ្លៃសេវាបែបនោះ (យ៉ាងហោចណាស់ទៅលើផ្នែកណាមួយ) ដែរឬទេ ?<br>• តើក្រុមប្រឹក្សាកម្រិតណាដែលមានលក្ខណសម្បត្តិស័ក្តិសមជាងគេដែលអាចពង្រឹងនូវគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ក្នុងការគ្រប់គ្រង និងអនុវត្តមុខងារ និងឬមុខងាររងនោះ?<br>• មុខងារ និងឬមុខងាររងចាំបាច់ដែលជះឥទ្ធិពលដោយផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ ការកែលំអគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន |
| ៤.មានផលប៉ះពាល់ចម្បងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនោះ | • តើមុខងារ និងឬមុខងាររងនោះ មានផលប៉ះពាល់ត្រឹមកម្រិតមូលដ្ឋាននោះ ឬលើសពីនោះ?<br>• តើនឹងមានផលប៉ះពាល់ឆ្លងដែនសមត្ថកិច្ចដែរឬទេ?<br>• តើនឹងមានផលប៉ះពាល់ខ្លាំងក្នុងមូលដ្ឋានដែរឬទេ? |

**កំណត់សម្គាល់ ៖**

- គោលការណ៍ទាំងនេះនឹងជួយដល់ក្រុមការងារបច្ចេកទេសក្នុងការថ្លឹងថ្លែងពីគុណសម្បត្តិ និងគុណវិបត្តិនៃការផ្ទេរមុខងារឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងកំណត់ពីកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិដែលមុខងារគួរត្រូវបានផ្ទេរទៅឱ្យ។
- ក្នុងករណីភាគច្រើន មុខងារទាំងមូល (រួមជាមួយនឹងមុខងាររងទាំងអស់នៃមុខងារនោះ) នឹងមានលក្ខណៈសមស្របទៅនឹងគោលការណ៍ខាងលើសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការផ្ទេរមុខងារទាំងមូលឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិមួយ អាចមានលក្ខណៈល្អប្រសើរ ពីព្រោះវានឹងមានប្រសិទ្ធភាពជាងក្នុងការគ្រប់គ្រង និងអនុវត្ត ជាជាងការផ្ទេរតែមុខងាររងមួយចំនួននៃមុខងារនោះ។
- ប៉ុន្តែមានករណីខ្លះ មុខងារទាំងមូលមួយមិនអាចមានលក្ខណៈសមស្របទៅនឹងគោលការណ៍ខាងលើនេះទេ។ ក្នុងករណីនេះក្រុមការងារបច្ចេកទេសត្រូវពិនិត្យមើលឡើងវិញនូវមុខងាររងនៃមុខងារនីមួយៗ ដើម្បីសម្រេចថា តើមានមុខងាររងណាខ្លះដែលសមស្របទៅនឹងគោលការណ៍ទាំងនោះសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

២. នៅពេលពិចារណាអំពីជម្រើសនានាសម្រាប់ការផ្ទេរមុខងាររង ក្រុមការងារបច្ចេកទេសត្រូវយកចិត្តទុកដាក់ចំពោះ ៖

- ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនូវមុខងារក្នុងការធ្វើសេចក្ដីសម្រេចអំពីរបៀបនៃការផ្ដល់សេវា និងអ្នកទទួលសេវា ប៉ុន្តែមិនផ្ទេរនូវមុខងារអនុវត្តជាក់ស្ដែងនៃសេវាទាំងនោះទេ (ឧទាហរណ៍ ក្រុមប្រឹក្សាឃុំសម្រេចថា ការបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់ក្មេងប្រុសក្នុងឃុំត្រូវផ្ដោតទៅលើការជួសជុលម៉ូតូ ប៉ុន្តែរដ្ឋបាលស្រុកជាអ្នកអនុវត្ត/ផ្ដល់សេវាបណ្ដុះបណ្ដាល)។
- ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនូវមុខងាររងដែលភាគច្រើនជាមុខងាររងក្នុងការអនុវត្ត ចំណែកឯមុខងារក្នុងការត្រួតពិនិត្យជារួមអាចរក្សាទុកនៅថ្នាក់ក្រសួង ស្ថាប័ន (ដែលជាករណីនៃការធ្វើប្រតិភូកម្មមុខងារ)។

៣. ក្រុមការងារបច្ចេកទេសត្រូវពិចារណាអំពីការផ្ទេររួមគ្នានូវមុខងារមួយក្នុងពេលដំណាលគ្នាជាមួយនឹងមុខងារមួយផ្សេងទៀត ប្រសិនបើមុខងារទាំងនោះមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ឧទាហរណ៍៖ មុខងារមួយចំនួនត្រូវបានផ្ដល់តាមរយៈមធ្យោបាយរួមគ្នានៅក្នុងមណ្ឌលសុខភាពមួយ ដូចជា សេវាគាំពារមាតា និងទារកមុនពេលសម្រាល ក្រោយពេលសម្រាល និងការពន្យារកំណើតជាដើម។

៤. ក្នុងករណីមានការលំបាកក្នុងការសម្រេចអំពីមុខងារ និងឬមុខងាររងដែលនឹងត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ ក្រុមការងារបច្ចេកទេសត្រូវពិនិត្យមើលឧបសម្ព័ន្ធទី២ដែលផ្តល់ពីគំនិតបន្ថែមសម្រាប់ការពិចារណា រួមទាំងជម្រើសនានាសម្រាប់ក្រសួង ស្ថាប័នដែលមានអង្គភាពរបស់ខ្លួននៅថ្នាក់ក្រោមជាតិ ដែលមានសមត្ថកិច្ចផ្តល់សេវាគ្របដណ្តប់លើភូមិសាស្ត្រច្រើនជាងមួយមណ្ឌលរដ្ឋបាលនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ (ឧទាហរណ៍៖ ស្រុកប្រតិបត្តិសុខាភិបាលមណ្ឌលសុខភាព)។

៥. ក្រុមការងារបច្ចេកទេសត្រូវស្រង់យកមុខងារ និងឬមុខងាររងដែលមានលក្ខណៈសមស្របទៅនឹងគោលការណ៍ខាងលើដាក់បញ្ចូលទៅក្នុងតារាងគំរូទី២ ដូចខាងក្រោម៖

## តារាងគំរូទី២ : តារាងសំណើនៃមុខងារ និងឬមុខងាររងដែលត្រូវពិនិត្យមើលឡើងវិញ

| មុខងារ | លិខិតបទដ្ឋានគតិយុត្តយោង | ស្ថាប័នអនុវត្ត | | | សំណើកម្រិតរដ្ឋបាល | ប្រគល់ ឬប្រតិភូកម្ម | មុខងារជាកាតព្វកិច្ច ឬជាជម្រើស |
|---|---|---|---|---|---|---|---|
| | | ទីស្តីការក្រសួង | មន្ទីរ អង្គភាព ខេត្ត រាជធានី | ការិយាល័យ ក្រុងស្រុក ខណ្ឌ | | | |
| **មុខងារទី១.........................** | | | | | | | |
| មុខងាររងទី១.១ | | | | | | | |
| មុខងាររងទី១.២. | | | | | | | |
| មុខងាររងទី... | | | | | | | |
| **មុខងារទី២.........................** | | | | | | | |
| មុខងាររងទី២.១. | | | | | | | |
| មុខងាររងទី២.២. | | | | | | | |
| មុខងាររងទី... | | | | | | | |
| **មុខងារទី៣.........................** | | | | | | | |
| មុខងាររងទី៣.១. | | | | | | | |
| មុខងាររងទី៣.២. | | | | | | | |
| មុខងាររងទី... | | | | | | | |

៦. ចំពោះមុខងារទាំងមូល ឬមានតែមុខងាររងណាមួយ ឬមួយចំនួនដែលមានលក្ខណៈសមស្របតាមគោលការណ៍សម្រាប់ការផ្ទេរឱ្យទៅដល់កម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ ក្រុមការងារបច្ចេកទេសត្រូវដាក់ពី**កម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ** (រាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ឬឃុំ សង្កាត់) ទៅក្នុងកូឡោន(**សំណើកម្រិតរដ្ឋបាល**)នៃតារាងគំរូទី២។ ចំពោះមុខងាររងដែលមិនមានលក្ខណៈសមស្របតាមគោលការណ៍សម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិណាមួយទេ មុខងាររងទាំងនោះនឹងនៅតែជាមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាដដែល ហើយក្រុមការងារបច្ចេកទេសត្រូវបញ្ជាក់ថា **ថ្នាក់ជាតិ** ទៅក្នុងកូឡោនសំណើកម្រិតរដ្ឋបាល។

៨. ក្រុមការងារបច្ចេកទេស ត្រូវគូសបញ្ជាក់ពីហេតុផលដែលមានលក្ខណៈសមស្របអំពីមុខងារ និងឬមុខងាររងដែលត្រូវស្នើឡើងសម្រាប់ផ្ទេរឱ្យទៅដល់កម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ ឬរក្សាទុកនៅថ្នាក់ជាតិនៅក្នុងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ។

៩. សម្រាប់មុខងារ និងឬមុខងាររងនីមួយៗដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរ ក្រុមការងារបច្ចេកទេសត្រូវបញ្ជាក់ថា មុខងារ ឬនិងមុខងាររងនោះជាមុខងារជា**កាតព្វកិច្ច** ឬ**មុខងារជាជម្រើស**។

**កំណត់សម្គាល់ ៖**

- មុខងារជាកាតព្វកិច្ច គឺជាមុខងារពាក់ព័ន្ធទៅនឹង**សេវាជាមូលដ្ឋាន និងចាំបាច់**ដែលត្រូវគ្រប់គ្រង ចាត់ចែង និងអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិអនុលោមទៅតាមបទដ្ឋាន និងនីតិវិធីដែលកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬលិខិតបទដ្ឋានគតិយុត្តនានាតាមសំណើរបស់ គ.ជ.អ.ប. ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិណាដែលទទួលបាននូវការផ្ទេរមុខងារជាកាតព្វកិច្ចពីក្រសួង ស្ថាប័ន **ត្រូវតែអនុវត្តនូវមុខងារនោះដោយខានពុំបាន**។ មុខងារជាកាតព្វកិច្ច អាចត្រូវបានផ្ទេរតាមរយៈការប្រគល់ ឬតាមរយៈការធ្វើប្រតិភូកម្ម។ ការប្រគល់ ឬការធ្វើប្រតិភូកម្មមុខងារជាកាតព្វកិច្ចត្រូវជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដោយ៖
    - ផ្តល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវអំណាចជាអតិប្បរមាដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងអស់នោះ
    - តម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងអស់នោះដោយមានការឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- មុខងារជាជម្រើស គឺជាមុខងារដែលពុំមានលក្ខណៈកាតព្វកិច្ច។ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិក្នុងការសម្រេចទទួលយល់ព្រមអនុវត្ត ឬមិនអនុវត្តចំពោះមុខងារជាជម្រើសដែលត្រូវបានផ្ទេរឱ្យដោយក្រសួង ស្ថាប័ន។ ក្រសួង ស្ថាប័នត្រូវផ្ទេរមុខងារជាជម្រើសទៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការប្រគល់។

១០. សម្រាប់មុខងារ ឬនិងមុខងាររងនីមួយៗដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមការងារបច្ចេកទេសត្រូវកំណត់ថា ការផ្ទេរមុខងារ និងឬមុខងាររងទាំងនេះត្រូវផ្ទេរតាមរយៈ**ការប្រគល់** ឬ**ការធ្វើប្រតិភូកម្ម**។

មុខងារដែលត្រូវបានប្រគល់នឹងក្លាយជា"មុខងារផ្ទាល់"របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយដែលក្រុមប្រឹក្សាអាចអនុវត្តដោយស្វ័យភាពនូវមុខងារនោះដោយមិនចាំបាច់មានការចូលរួម ឬជំនួយជាប្រចាំពីក្រសួង ស្ថាប័នឡើយ។

មុខងារដែលត្រូវបានធ្វើប្រតិភូកម្ម នៅតែបន្តជាមុខងារដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរនោះដដែល ប៉ុន្តែក្រុមប្រឹក្សាត្រូវមានតួនាទីក្នុងការអនុវត្តមុខងារនោះក្នុងនាមជាតំណាង និងស្របទៅតាមការណែនាំរបស់ក្រសួង ស្ថាប័ននោះ។

១១. ក្នុងករណីខ្លះ ក្រុមការងារបច្ចេកទេសអាចស្នើឡើងនូវរបៀបអនុវត្តខុសគ្នានៃការផ្ទេរមុខងារចំពោះក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្រិតដូចគ្នា (ឧទាហរណ៍៖ ក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្រុង ស្រុកមួយចំនួនអាចទទួលបាននូវមុខងារមួយចំណែកឯក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ផ្សេងទៀតមិនទទួលបាននូវមុខងារបែបនោះទេ)។

**កំណត់សំគាល់៖**

- ជាឧទាហរណ៍១ : ក្នុងករណីខ្លះ វានឹងមានប្រសិទ្ធិភាពក្នុងការផ្ទេរមុខងារមួយទៅឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ឬក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកដែលមានអាត្រាប្រជាជនច្រើន ផ្ទុយទៅវិញ វាអាចនឹងមិនមានប្រសិទ្ធិភាពទេក្នុងការផ្ទេរមុខងារដូចគ្នាទៅឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ឬក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ដែលមានអាត្រាប្រជាជនតិច។
- ឧទាហរណ៍២ : សម្រាប់ក្រុងនានាដែលជាក្រុងនៃទីរួមខេត្ត វាអាចនឹងមិនមានប្រសិទ្ធិភាពទេប្រសិនបើផ្ទេរទៅឱ្យក្រុងទាំងនេះនូវមុខងារដូចគ្នានឹងមុខងារ ដែលគ្រប់គ្រងដោយក្រុងផ្សេងទៀតដែលមិនមែនជាក្រុងនៃទីរួមខេត្ត ប៉ុន្តែវាអាចនឹងមានប្រសិទ្ធិភាពជាងប្រសិនបើក្រុងទាំងនោះទទួលបាននូវការផ្ទេរមុខងារ ដែលត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាខេត្ត។ ហេតុដូចនេះ របៀបនៃការផ្ទេរអាចប្រែប្រួលទៅតាមស្ថានភាពខុសៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដូចជាទំហំ ឬសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះដោយសំអាងលើហេតុផលថា បើទោះជាក្រុមប្រឹក្សាទាំងនោះ

ទទួលបាននូវធនធាន និងការកសាងសមត្ថភាពក្នុងការអនុវត្តមុខងារក៏ដោយក៏ក្រុមប្រឹក្សាមួយចំនួននៅកម្រិតនោះ នៅមិនទាន់អាចមានលក្ខណៈសមស្របក្នុងការអនុវត្តមុខងារទាំងនោះបានដែរ ។

១២. ប្រសិនបើក្រុមការងារបច្ចេកទេស កំណត់ថាមុខងារមួយត្រូវបានផ្ទេរតាមរបៀបខាងលើ ក្រុមការងារបច្ចេកទេសត្រូវកំណត់ពីលក្ខណៈទូទៅនៃកម្រិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បន្ទាប់មកទើបកំណត់ពីរដ្ឋបាលថ្នាក់ក្រោមជាតិជាក់លាក់ដែលត្រូវទទួលមុខងារទាំងនោះ ។

១៣. ក្រុមការងារបច្ចេកទេសត្រូវស្រង់មុខងារ ឬមុខងាររងទាំងអស់ដែលត្រូវបានស្នើឡើងសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមកម្រិតនីមួយៗដោយបំពេញនូវតារាងស្តីពីមុខងារ ឬមុខងាររង ដែលត្រូវផ្ទេរតាមកម្រិតនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ (តារាងគំរូទី៣) ។

១៤. ក្នុងការពិនិត្យមើលឡើងវិញនូវមុខងារ ដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្រិតនីមួយៗ ក្រុមការងារបច្ចេកទេសត្រូវធានាថារដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្រិតនីមួយៗទទួលបាននូវមុខងារ ឬនិងមុខងាររងនានាដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្ត ។

**កំណត់សំគាល់** :

- ឧទាហរណ៍ ចំពោះការផ្ទេរមុខងារទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ គួរផ្ទេរមុខងារក្នុងការសាងសង់ ថែទាំ និងជួសជុល ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្រិតណាមួយ ជាជាងការផ្ទេរមុខងារក្នុងការសាងសង់ឱ្យរដ្ឋបាលថ្នាក់មួយ មុខងារថែទាំឱ្យរដ្ឋបាលថ្នាក់មួយផ្សេងទៀត ហើយមុខងារជួសជុលឱ្យរដ្ឋបាលថ្នាក់មួយផ្សេងទៀត ។

១៥. ក្រុមការងារបច្ចេកទេសត្រូវធានាផងដែរថា មុខងារ និងឬមុខងាររងដែលត្រូវផ្ទេរទាំងអស់នោះមានលក្ខណៈសមហេតុផល ក្នុងការសម្រេចបាននូវអាទិភាពនានាក្នុងវិស័យរបស់ក្រសួង ស្ថាប័ន បើទោះជាសំណើក្នុងការផ្ទេរមុខងារនោះនាំឱ្យមានការកែសម្រួលវិធីសាស្ត្រ និងផែនការបច្ចុប្បន្ននៃវិស័យទាំងនោះក៏ដោយ ។

១៦. ក្រុមការងារត្រូវរៀបចំកិច្ចប្រជុំ ពិគ្រោះយោបល់ផ្ទៃក្នុងក្រសួង ស្ថាប័ន លើសំណើនៃការផ្ទេរមុខងារ និងឬមុខងាររងដែលបានរៀបចំក្នុងតារាងគំរូទី២ និងទី៣ ។

### តារាងគំរូទី៣ : តារាងស្តីពីមុខងារ ឬមុខងាររងដែលត្រូវបានស្នើឡើងសម្រាប់ផ្ទេរទៅតាមកម្រិតនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

| មុខងារ | មុខងាររង | ជាតិ | រាជធានី | ខេត្ត | ស្រុក | ក្រុង | ខណ្ឌ | ឃុំ | សង្កាត់ | ការផ្ទេរ | | ប្រភេទមុខងារ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ប្រតិភូកម្ម | ប្រគល់ | កាតព្វកិច្ច | ជម្រើស |
| ១. | ១.១ | | | | | | | | | | | | |
| | ១.២ | | | | | | | | | | | | |
| | ១.៣ | | | | | | | | | | | | |
| | ១.៤ | | | | | | | | | | | | |
| ២. | ២.១ | | | | | | | | | | | | |
| | ២.២ | | | | | | | | | | | | |
| | ២.៣ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៣. | ៣.១ | | | | | | | | | | | | |
| | ៣.២ | | | | | | | | | | | | |
| | | | | | | | | | | | | | |

# ជំហានទី៣
# ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

## ក. គោលបំណង

គោលបំណងនៃជំហានទី៣នេះ គឺដើម្បីធានាថាមុខងារ និងឬមុខងាររងដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ មានលក្ខណៈប្រទាក់ក្រឡាគ្នានៅក្នុងចំណោមក្រសួង ស្ថាប័ននានា។

## ខ. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកក្នុងជំហាននេះ គឺការកែតម្រូវលើមុខងារ និងឬមុខងាររងនៅក្នុងតារាងគំរូទី៣ដែលត្រូវបានស្នើឡើងសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## គ. ដំណើរការ

ក្នុងការអនុវត្តជំហានទី៣នេះ ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថានីមួយៗត្រូវអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម :

១. បន្ទាប់ពីបានបញ្ចប់ជំហានទី២ ក្រុមការងារបច្ចេកទេសត្រូវកំណត់អំពីក្រសួង ស្ថាប័ននានាដែលពាក់ព័ន្ធនឹងមុខងារ និងឬមុខងាររងដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិដូចមាននៅក្នុងតារាងគំរូទី៣។

២. ក្រសួង ស្ថាប័នសាមីត្រូវរៀបចំកិច្ចប្រជុំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះ ដើម្បីពិគ្រោះយោបល់អំពីភាពប្រទាក់ក្រឡាគ្នានៃមុខងារ និងឬមុខងាររងដែលបានស្នើឡើងជាមួយនឹងមុខងារ និងឬមុខងាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីចាំបាច់ ក្រសួង ស្ថាប័នសាមីអាចស្នើសុំឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប ជួយសម្របសម្រួលក្នុងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នេះ។

៣. ក្នុងករណីខ្លះ ក្រសួង ស្ថាប័នមួយចំនួនអាចនឹងមានមុខងារត្រួតគ្នា ឬមុខងារដែលអនុវត្តរួមគ្នា ឬមុខងារដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយក្រសួង ស្ថាប័នមួយផ្សេងទៀត ដែលចាំបាច់ត្រូវមានវិធីសាស្ត្ររួមមួយសម្រាប់ការអនុវត្តមុខងារទាំងនោះ ទើបធានាបាននូវប្រសិទ្ធភាព (ឧទាហរណ៍ : មុខងាររៀបចំកម្មសិក្សាបន្ថែមនៅក្នុងសាលាបឋមសិក្សាមួយត្រូវផ្ទេរឱ្យទៅដល់ក្រុមប្រឹក្សាស្រុក ដូចនេះមុខងារនៃការរៀបចំកម្មវិធីសុខភាពក្នុងសាលាក៏ត្រូវបានផ្ទេរទៅក្រុមប្រឹក្សាស្រុកផងដែរ)។

៤. ប្រសិនបើមុខងារដែលត្រួតគ្នា ឬអនុវត្តរួមគ្នា ឬលក្ខណៈប្រហាក់ប្រហែលគ្នា ត្រូវបានស្នើឡើង

សម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នត្រូវព្យាយាមសម្របសម្រួលដើម្បីឱ្យមានការឯកភាពគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះ ក្នុងការកំណត់តួនាទី និងយន្តការសម្របសម្រួលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអនុវត្តមុខងារ និងឬមុខងាររងទាំងនោះ។

៥. ការពិភាក្សាជាមួយបណ្ដាក្រសួង ស្ថាប័នផ្សេងទៀត អាចនឹងតម្រូវឱ្យក្រុមការងារបច្ចេកទេសធ្វើការកែសម្រួលព័ត៌មាននានាដែលមាននៅក្នុងតារាងទី៣ ផ្អែកតាមលទ្ធផលនៃការពិភាក្សា។ ក្នុងករណីដែលតម្រូវឱ្យមានការកែសម្រួល ក្រុមការងារបច្ចេកទេសត្រូវយកតារាងទី៣នេះ មកធ្វើការកែសម្រួលដើម្បីបង្កើតបានជាតារាងទី៤ដូចខាងក្រោម។

### តារាងគំរូទី៤ ៖ តារាងស្តីពីមុខងារ ឬមុខងាររងដែលត្រូវបានស្នើឡើងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

| មុខងារ | មុខងាររង | ជាតិ | រាជធានី | ខេត្ត | ស្រុក | ក្រុង | ខណ្ឌ | ឃុំ | សង្កាត់ | ការផ្ទេរ | | ប្រភេទមុខងារ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ប្រតិភូកម្ម | ប្រគល់ | កាតព្វកិច្ច | ជម្រើស |
| ១. | ១.១ | | | | | | | | | | | | |
| | ១.២ | | | | | | | | | | | | |
| | ១.៣ | | | | | | | | | | | | |
| | ១.៤ | | | | | | | | | | | | |
| ២. | ២.១ | | | | | | | | | | | | |
| | ២.២ | | | | | | | | | | | | |
| | ២.៣ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៣. | ៣.១ | | | | | | | | | | | | |
| | ៣.២ | | | | | | | | | | | | |
| | | | | | | | | | | | | | |

# ជំហានទី ៤
# ការកំណត់នូវធនធាននានា ដែលត្រូវប្រើប្រាស់ដើម្បីអនុវត្ត មុខងារដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរ

## ក. គោលបំណង

គោលបំណងនៃជំហានទី៤នេះ គឺដើម្បីកំណត់ពីធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកដែលមាននៅក្នុងរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តមុខងារ ដែលត្រូវបានស្នើឡើងសម្រាប់ផ្ទេរទៅឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ខ. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកក្នុងជំហាននេះ គឺការបន្ថែមនូវព័ត៌មានស្តីពីធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកនៅក្នុងតារាងគំរូទី៣សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តមុខងារ ដែលត្រូវបានស្នើឡើងសម្រាប់ផ្ទេរទៅឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## គ. ដំណើរការ

ក្នុងការអនុវត្តជំហានទី៤នេះ ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័នមួយៗត្រូវអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម :

១. ក្រុមការងារបច្ចេកទេសត្រូវពិនិត្យមើលឡើងវិញនូវធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកសម្រាប់អនុវត្តមុខងារ និងមុខងាររងនីមួយៗ ដែលមាននៅក្នុងរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន ដើម្បីកំណត់នូវធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកសមស្របសម្រាប់អនុវត្តមុខងារ និងឬមុខងាររងដែលបានស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

២. នៅពេលដែលរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារ មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីធនធានហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិចាំបាច់សម្រាប់ធ្វើការផ្ទេរព្រមគ្នាជាមួយមុខងារ និងឬមុខងាររង ក្រុមការងារបច្ចេកទេសត្រូវធ្វើការបញ្ជាក់ព័ត៌មាន ឬស្វែងរកនូវព័ត៌មានដែលខ្វះខាតសម្រាប់បំពេញឱ្យមុខងារ និងឬមុខងាររងជាក់លាក់ទាំងនោះ ។

៣. ប្រសិនបើក្រុមការងារបច្ចេកទេសជឿជាក់ថា រដ្ឋបាលថ្នាក់ក្រោមជាតិអាចនឹងត្រូវការធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ ឬបុគ្គលិកបន្ថែមពីលើអ្វីដែលបានភ្ជាប់ជាមួយមុខងារ ខ្លួនត្រូវកត់ត្រានូវការកត់សម្គាល់ចំនុចនេះ ដើម្បីសង្ខេបទៅក្នុងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ

៤. បន្ទាប់ពីកំណត់បាននូវធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកសមស្របសម្រាប់អនុវត្តមុខងារ និងឬមុខងាររងដែលបានស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមការងារបច្ចេកទេសត្រូវស្រង់បញ្ចូលក្នុងតារាងគំរូទី៥ ។

## តារាងគំរូទី៥ ៖តារាងមុខងារ មុខងាររង និងធនធានដែលស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

| *កូដមុខងារ* | កូដមុខងាររង | ជាតិ | រាជធានី | ខេត្ត | ក្រុង | ស្រុក | ខណ្ឌ | ឃុំ | សង្កាត់ | ធនធាន | | | ការផ្ទេរ | | ប្រភេទមុខងារ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ហិរញ្ញវត្ថុ | ទ្រព្យសម្បត្តិ | បុគ្គលិក | ប្រគល់ | ប្រតិភូកម្ម | កាតព្វកិច្ច | ជម្រើស |
| ១. | ១.១ | | | | | | | | | | | | | | | |
| | ១.២ | | | | | | | | | | | | | | | |
| | ១.៣ | | | | | | | | | | | | | | | |
| | ១.៤ | | | | | | | | | | | | | | | |
| ២. | ២.១ | | | | | | | | | | | | | | | |
| | ២.២ | | | | | | | | | | | | | | | |
| | ២.៣ | | | | | | | | | | | | | | | |
| | ២.៤ | | | | | | | | | | | | | | | |
| | ២.៥ | | | | | | | | | | | | | | | |

# ជំហានទី ៥
# ការរៀបចំវិធីសាស្ត្រសម្រាប់ការផ្ទេរមុខងារ និងធនធានដែលត្រូវបានស្នើឡើង

## ក. គោលបំណង

គោលបំណងនៃជំហានទី៥ នេះគឺដើម្បីរៀបចំវិធីសាស្ត្រសម្រាប់ការផ្ទេរមុខងារ និងធនធានចាំបាច់ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ខ. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកនៃជំហានទី៥នេះ គឺការកំណត់បាននូវវិធីសាស្ត្រសម្រាប់ផ្ទេរមុខងារ និងធនធានដែលភ្ជាប់ជាមួយមុខងារនោះ។

## គ. ដំណើរការ

ក្នុងកិច្ចដំណើរការជំហាននេះ ក្រុមការងារបច្ចេកទេសត្រូវកំណត់នូវវិធីសាស្ត្រនានាសម្រាប់ការផ្ទេរមុខងារ និងឬមុខងាររងនីមួយៗឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ វិធីសាស្ត្រដែលក្រុមការងារបច្ចេកទេសអាចពិចារណារួមមាន :

### ១. វិធីសាស្ត្រផ្ទេរជាដំណាក់កាល

- ក្នុងការអនុវត្តវិធីសាស្ត្រនេះ ក្នុងដំណាក់កាលដំបូង ក្រុមការងារបច្ចេកទេសអាចស្នើឱ្យមានការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនូវមុខងារ និងឬមុខងាររងមួយចំនួនប៉ុណ្ណោះ។ ឧទាហរណ៍ : ក្រសួងអប់រំ យុវជន និងកីឡាជាដំបូងអាចផ្ទេរឱ្យទៅដល់រដ្ឋបាលស្រុកនូវមុខងារមួយចំនួនដែលទាក់ទងទៅនឹងការអប់រំកម្រិតបឋម បន្ទាប់មកទៀតទើបធ្វើការផ្ទេរមុខងារដែលទាក់ទងទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យទៅដល់រដ្ឋបាលស្រុក។ ការផ្ទេរជាដំណាក់កាលបែបនេះនឹងផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវឱកាសទទួលយកនូវមុខងារថ្មីបន្តិចម្តងៗពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរនានា។
- ដោយផ្អែកទៅលើតារាងគំរូទី៥ស្តីពីមុខងារ និងឬមុខងាររង និងធនធានដែលស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមការងារបច្ចេកទេសអាចស្នើឡើងនូវមុខងារមួយចំនួនប៉ុណ្ណោះសម្រាប់ការផ្ទេរក្នុងរយៈពេលខ្លី។ មុខងារ និងឬមុខងាររងដែលគួរពិចារណាសម្រាប់ការផ្ទេរក្នុងរយៈពេលខ្លីរួមមាន ៖
  - មុខងារ និងមុខងាររងដែលមានភាពសាមញ្ញ និងងាយស្រួលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត ហើយដែលមិនតម្រូវឱ្យមានការគាំទ្រពីក្រសួង ស្ថាប័ន

- មុខងារ និងឬមុខងាររងដែលកំពុងត្រូវបានអនុវត្ត និងត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់ ហើយដែលមានធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកភ្ជាប់ជាមួយរួចហើយ
- មុខងារ និងឬមុខងាររងដែលមិនតម្រូវឱ្យមានការសម្របសម្រួល ឬកិច្ចសហការឆ្លងវិស័យ
- មុខងារ និងឬមុខងាររងដែលរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនបានផ្តួចផ្តើមយកមកអនុវត្តដោយជោគជ័យរួចហើយ និងអាចក្លាយទៅជាមុខងារជាកាតព្វកិច្ចបាន
- មុខងារ និងឬមុខងាររងដែលធ្លាប់បានអនុវត្តដោយជោគជ័យនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសដទៃ ។

- បន្ទាប់មកទៀតក្រុមការងារបច្ចេកទេស អាចស្នើឱ្យមានការផ្ទេរនូវមុខងារមួយចំនួនក្នុងលក្ខណៈជាប្រព័ន្ធទៅតាមទីតាំងភូមិសាស្ត្រជាក់លាក់មួយចំនួនជាមុនសិន មុននឹងផ្ទេរទៅឱ្យគ្រប់ទីកន្លែងនៅទូទាំងប្រទេស ។ ឧទាហរណ៍ : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចផ្ទេរមុខងារក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក ជាដំបូងអាចនៅតំបន់ភាគពាយ័ព្យ បន្ទាប់មកអាចផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកនៅតំបន់ភាគឦសាន និងចុងក្រោយផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកទាំងអស់ដែលនៅសេសសល់ ។ ចំណែកមុខងារក្នុងការផ្តល់កម្មវិធីសិក្សាសាលាមត្តេយ្យរដ្ឋ ដំបូងអាចផ្ទេរឱ្យទៅដល់រដ្ឋបាលនៅតំបន់ទីប្រជុំជនមុនពេលផ្ទេរមុខងារនេះឱ្យទៅដល់រដ្ឋបាលនៅតំបន់ដាច់ស្រយាល ។ ការផ្ទេរជាដំណាក់កាលបែបនេះ ត្រូវពិចារណាអំពីសមត្ថភាពរបស់ក្រសួង ស្ថាប័នក្នុងការគ្រប់គ្រង គាំទ្រ និងតាមដានការអនុវត្តទូទាំងប្រទេសក្នុងពេលតែមួយ ។
- ក្រុមការងារបច្ចេកទេស អាចស្នើឱ្យប្រើប្រាស់នូវវិធីណាមួយ ឬវិធីទាំងពីរខាងលើដើម្បីផ្ទេរមុខងារជាដំណាក់កាល ឬមិនប្រើប្រាស់វិធីណាមួយ ។ ក្រុមការងារបច្ចេកទេសត្រូវលើកឡើងអំពីសំណើវិធីសាស្ត្រនៃការផ្ទេរជាដំណាក់កាលនេះដោយមានការគូសបញ្ជាក់ពីហេតុផលដែលមានសនិទានភាពច្បាស់លាស់ ។

## ២. វិធីសាស្ត្រនៃការផ្ទេរមានលក្ខណៈជាការសាកល្បង

- ការផ្ទេរមុខងារ និងឬមុខងាររងណាមួយតាមរយៈវិធីសាស្ត្រសាកល្បងនឹងផ្តល់នូវមេរៀន និងបទពិសោធន៍សម្រាប់ក្រសួង ស្ថាប័នធ្វើជាមូលដ្ឋានក្នុងធ្វើសេចក្តីសម្រេចចិត្តក្នុងការផ្ទេរមុខងារ និងឬមុខងាររងនោះជាលក្ខណៈអចិន្ត្រៃយ៍ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ ការផ្ទេរមុខងារ និងឬមុខងាររងតាមរយៈវិធីសាស្ត្រសាកល្បងអាចមានលក្ខណៈសមស្របជាង ប្រសិនបើនៅមានភាពមិនប្រាកដប្រជាថា រដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលយកមុខងារ និងឬមុខងាររងមួយទៅអនុវត្តបានដោយជោគជ័យ ឬនៅពេលមានភាពមិនច្បាស់លាស់អំពីកម្រិតស្តង់ដារ

នៃការផ្តល់សេវា និងការលើកកម្ពស់គុណភាពនៃសេវាជាដើម។ ភាពមិនប្រាកដប្រជានេះអាចបណ្តាលមកពីមូលហេតុនៃការខ្វះខាតព័ត៌មាន ឬការពុំទាន់មានការឯកភាពគ្នាទៅលើវិធីសាស្ត្រដែលល្អប្រសើរបំផុតណាមួយ ឬកង្វះខាតនូវធនធានដែលចាំបាច់។

- ការផ្ទេរមុខងារ និងឬមុខងាររងណាមួយតាមរយៈវិធីសាស្ត្រសាកល្បងនេះនឹងមានភាពសមស្របផងដែរ ប្រសិនបើមានភាពមិនច្បាស់លាស់ពីតម្រូវការនៃសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចអនុវត្តមុខងារ និងឬមុខងាររងប្រកបដោយជោគជ័យ ឬភាពមិនច្បាស់លាស់ពីរបៀបនៃការកសាងសមត្ថភាព និងការគាំទ្រជាបន្តបន្ទាប់ពីក្រសួង ស្ថាប័ន។ ដូចនេះ ការផ្ទេរមុខងារ និងឬមុខងាររងទៅតាមរយៈវិធីសាស្ត្រសាកល្បងអាចនឹងឆ្លើយតបទៅនឹងតម្រូវការសមត្ថភាព និងជាវិធីសាស្ត្រដែលល្អប្រសើរសម្រាប់ដោះស្រាយបញ្ហាទាំងនេះ។
- ប្រសិនបើក្រសួង ស្ថាប័នសម្រេចឱ្យមានការផ្ទេរមុខងារ និងឬមុខងាររងណាមួយតាមរយៈវិធីសាស្ត្រសាកល្បង ចាំបាច់តម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀតក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងក្នុងការរៀបចំកម្មវិធីសាកល្បងនេះ។
- ដំណើរការនៃការផ្ទេរមុខងារ និងឬមុខងាររងតាមរយៈវិធីសាស្ត្រសាកល្បងត្រូវ :
  - មានគោលបំណងច្បាស់លាស់ និងជាក់លាក់
  - មានការរៀបចំកម្មវិធីច្បាស់លាស់ ដែលអាចធានាឱ្យមាននិរន្តរភាព និងអាចពង្រីកទៅរកទ្រង់ទ្រាយធំ ប្រសិនបើការអនុវត្តកម្មវិធីសាកល្បងនេះទទួលបានជោគជ័យ (ទោះបីជាកម្មវិធីសាកល្បងនេះត្រូវបានគាំដោយថវិការបស់ដៃគូអភិវឌ្ឍន៍ក៏ដោយ ក៏ធនធានដែលត្រូវប្រើប្រាស់សម្រាប់កម្មវិធីសាកល្បងនេះ ត្រូវមានភាពសមស្របទៅនឹងធនធានក្នុងប្រព័ន្ធរាជរដ្ឋាភិបាល)
  - មានធនធានសមស្រប រួមបញ្ចូលទាំងធនធានសម្រាប់ការតាមដាន និងវាយតម្លៃដែលត្រូវធ្វើឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធ រួមគ្នាជាមួយនឹងលេខាធិការដ្ឋាន គ.ជ.អ.ប.។
- ក្រុមការងារបច្ចេកទេសត្រូវគូសបញ្ជាក់នូវសំណើមុខងារ និងឬមុខងាររងដែលត្រូវផ្ទេរតាមវិធីសាស្ត្រសាកល្បងដោយមានការគូសបញ្ជាក់ពីហេតុផលដែលមានសនិទានភាពច្បាស់លាស់។

# ជំហានទី ៦
# ការពិគ្រោះយោបល់ និងប្រមូលព័ត៌មាននៅថ្នាក់ក្រោមជាតិ

## ក. គោលបំណង

គោលបំណងនៃជំហានទី៦នេះ គឺដើម្បីធ្វើការពិគ្រោះយោបល់ និងប្រមូលព័តិមានពីអ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ដើម្បីធានាថា សំណើ និងជម្រើសនានាអំពីមុខងារ និងធនធាន និងវិធីសាស្ត្រក្នុងការផ្ទេរដែលត្រូវបានស្នើឡើងសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តបាន និងអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ។

## ខ. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកនៃជំហានទី៦នេះ គឺការរៀបចំបាននូវរបាយការណ៍ស្តីពីការពិគ្រោះយោបល់និងការប្រមូលព័តិមាននៅថ្នាក់ក្រោមជាតិ និងការកែសម្រួលតារាងស្តីពីមុខងារ ឬមុខងាររង និងធនធានដែលស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (តារាងទី៥) ។

## គ. ដំណើរការ

ក្នុងការអនុវត្តជំហានទី៦នេះ ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័នមួយៗត្រូវអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម :

១. ក្រុមការងារបច្ចេកទេស ត្រូវរៀបចំក្រុមការងារ ផែនការសកម្មភាព កំណត់ពេលវេលា និងកំណត់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់គោលដៅសម្រាប់ចុះទៅពិគ្រោះយោបល់ និងប្រមូលព័តិមាន

២. ក្នុងការចុះទៅពិគ្រោះយោបល់ និងប្រមូលព័តិមាន ក្រុមការងារបច្ចេកទេសត្រូវជ្រើសរើស ៖

- ខេត្តយ៉ាងតិចចំនួនបី ដែលខេត្តមួយក្នុងចំណោមនោះជាខេត្តដែលក្រសួង ស្ថាប័នធ្លាប់បានចុះទៅសិក្សានៅក្នុងអំឡុងដំណើរការរៀបចំបញ្ជីវិភាគមុខងារ
- ក្រុងទាំងអស់នៅក្នុងខេត្តដែលបានជ្រើសរើស
- សង្កាត់យ៉ាងតិចចំនួនបីនៅក្នុងខេត្តគោលដៅនីមួយៗដែលសង្កាត់មួយក្នុងចំណោមនោះ ក្រសួង ស្ថាប័នធ្លាប់បានចុះទៅសិក្សានៅក្នុងអំឡុងដំណើរការរៀបចំបញ្ជីវិភាគមុខងារ
- ស្រុកយ៉ាងតិចចំនួនបួននៅក្នុងខេត្តគោលដៅនីមួយៗ ដែលស្រុកមួយក្នុងចំណោមនោះក្រសួង ស្ថាប័នធ្លាប់បានចុះទៅសិក្សានៅក្នុងអំឡុងដំណើរការរៀបចំបញ្ជីវិភាគមុខងារ
- ឃុំយ៉ាងតិចចំនួនបួននៅក្នុងខេត្តគោលដៅនីមួយៗដែលឃុំមួយក្នុងចំណោមនោះក្រសួង ស្ថាប័នធ្លាប់បានចុះទៅសិក្សានៅក្នុងអំឡុងដំណើរការរៀបចំបញ្ជីវិភាគមុខងារ ។

៣. នៅពេលធ្វើការជ្រើសរើសខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ក្រុមការងារបច្ចេកទេសត្រូវពិចារណាទៅលើ ៖

- បែបផែននៃការផ្តល់សេវាសម្រាប់មុខងារដែលបានស្នើ
- ការគ្របដណ្តប់លើតំបន់ដែលមានលក្ខណៈផ្សេងៗគ្នា
- អត្រានៃភាពក្រីក្រ
- ចំនួនប្រជាពលរដ្ឋ និងដង់ស៊ីតេ
- ស្ថានភាពខុសៗគ្នានៃប្រជាពលរដ្ឋ
- ភាពដាច់ស្រយាល និង
- ស្ថានភាពដទៃទៀតពាក់ព័ន្ធនឹងក្រសួង ស្ថាប័នសាមី ។

៤. ក្រុមការងារបច្ចេកទេសត្រូវសម្រេចពីវិធីសាស្ត្រ និងពេលវេលាដែលតម្រូវឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនៅក្នុងជំហានទី៦ (សូមមើលឧបសម្ព័ន្ធ១) ។

៥. ក្នុងការចុះពិគ្រោះយោបល់ និងប្រមូលព័ត៌មាននេះ ក្រុមការងារបច្ចេកទេសត្រូវធ្វើបទសម្ភាសន៍ជាមួយមន្ត្រីក្នុងរចនាសម្ព័ន្ធរបស់៖

- មន្ទីរ អង្គភាព និងការិយាល័យជំនាញរបស់ក្រសួង ស្ថាប័នសាមី ព្រមទាំងមន្ទីរ អង្គភាពជំនាញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិ
- ក្រុមប្រឹក្សា *(សមាជិកក្រុមប្រឹក្សា)*
- រដ្ឋបាលរបស់ក្រុមប្រឹក្សា *(យ៉ាងហោចណាស់តំណាងគណៈអភិបាល)* និង
- សមាគមវិជ្ជាជីវៈដែលពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងក្រុមអ្នកប្រើប្រាស់សេវា ។

៦. ក្រុមការងារបច្ចេកទេសត្រូវរៀបចំនូវបទបង្ហាញជាសង្ខេបអំពីគោលបំណងនៃការជួបសម្ភាសន៍នេះដល់អ្នកពាក់ព័ន្ធនានាដែលខ្លួនត្រូវជួប ។ បទបង្ហាញនេះគួរលើកឡើងអំពីគោលការណ៍នានានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ព្រមទាំងសង្ខេបពីគំនិតផ្តួចផ្តើមជាបឋមរបស់ក្រុមការងារបច្ចេកទេសក្នុងកិច្ចដំណើរការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៧. បញ្ហាដែលត្រូវស្វែងយល់រួមគ្នាជាមួយអ្នកពាក់ព័ន្ធ (ទាំងបុរស ទាំងស្ត្រី) រួមមាន :

- តើអ្នកពាក់ព័ន្ធយល់ឃើញថា មុខងារដែលត្រូវបានស្នើឡើងសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិមានភាពសមស្របដែរឬទេ បើគិតពីកម្រិត និងវិសាលភាពនៃមុខងារទាំងនោះ? តើអ្នកពាក់ព័ន្ធទាំងអស់យល់ថារដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតនោះអាចគ្រប់គ្រង និងអនុវត្តមុខងារទាំងនោះបានដែរឬទេ ?

- តើអ្នកពាក់ព័ន្ធយល់ឃើញថា មានមុខងារណាខ្លះទៀតដែលគួរផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតណាមួយ?
- តើអ្នកពាក់ព័ន្ធយល់ថា រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាព និងលទ្ធភាពអ្វីខ្លះរួចហើយក្នុងការអនុវត្តមុខងារដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរនេះ?
- តើអ្នកពាក់ព័ន្ធយល់ថាសមត្ថភាព និងលទ្ធភាពអ្វីខ្លះដែលត្រូវការចាំបាច់សម្រាប់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តមុខងារនោះដោយជោគជ័យ?

៨. ក្រុមការងារបច្ចេកទេស វិភាគព័ត៌មានដែលប្រមូលបាននៅថ្នាក់ក្រោមជាតិ និងរៀបចំរបាយការណ៍។

៩. ក្រុមការងារបច្ចេកទេស ត្រូវរៀបចំកិច្ចប្រជុំដើម្បីពិភាក្សាលើរបាយការណ៍ស្តីពីលទ្ធផលនៃការពិគ្រោះយោបល់ និងការប្រមូលព័ត៌មាននៅមូលដ្ឋាន បន្ទាប់មកធ្វើការសម្រេចចិត្តក្នុងការកែសម្រួលសំណើ ឬជម្រើសនានាដែលបានលើកឡើងទៅតាមការចាំបាច់។ ក្នុងករណីមានការកែសម្រួលនូវសំណើឬជម្រើសទាំងនោះ ក្រុមការងារបច្ចេកទេសត្រូវធ្វើការកែសម្រួលនូវព័ត៌មាននៅក្នុងតារាងទី៥ ដើម្បីបង្កើតតារាងថ្មីមួយតាមតារាងគំរូទី៦ ដូចខាងក្រោម។

១០.ក្នុងករណីមានការកែសម្រួលសំណើ និងជម្រើសទាំងនោះ ក្រុមការងារបច្ចេកទសក៏ត្រូវគូសបញ្ជាក់នូវហេតុផល និងសនិទានភាពច្បាស់លាស់នៅក្នុងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័នផងដែរ។

## តារាងគំរូទី៦៖ មុខងារ មុខងាររង និងធនធានដែលស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិបន្ទាប់ពីការពិគ្រោះយោបល់ជាមួយថ្នាក់ក្រោមជាតិ

| *កូដមុខងារ* | កូដមុខងាររង | ជាតិ | រាជធានី | ខេត្ត | ក្រុង | ស្រុក | ខណ្ឌ | ឃុំ | សង្កាត់ | ធនធាន | | | ការផ្ទេរ | | ប្រភេទមុខងារ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ហិរញ្ញវត្ថុ | ទ្រព្យសម្បត្តិ | បុគ្គលិក | ប្រគល់ | ប្រតិភូកម្ម | កាតព្វកិច្ច | ជម្រើស |
| ១. | ១.១ | | | | | | | | | | | | | | | |
| | ១.២ | | | | | | | | | | | | | | | |
| | ១.៣ | | | | | | | | | | | | | | | |
| | ១.៤ | | | | | | | | | | | | | | | |
| ២. | ២.១ | | | | | | | | | | | | | | | |
| | ២.២ | | | | | | | | | | | | | | | |
| | ២.៣ | | | | | | | | | | | | | | | |
| | ២.៤ | | | | | | | | | | | | | | | |
| | ២.៥ | | | | | | | | | | | | | | | |

# ជំហានទី៧
# ការរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពី
# ការពិនិត្យមើលមុខងារឡើងវិញ

## ក. គោលបំណង

គោលបំណងនៃជំហានទី៧នេះ គឺដើម្បីរៀបចំនូវសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន ដែលបង្ហាញពីដំណើរការក្នុងការអនុវត្តការពិនិត្យមើលមុខងារ និងធនធានឡើងវិញ និងការលើកឡើងជាសំណើ ឬជម្រើសនានាសម្រាប់ការផ្ទេរមុខងារ និងធនធានរបស់ក្រសួង ស្ថាប័នឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិដោយមានការគូសបញ្ជាក់ពីហេតុផល និងសនិទានភាពច្បាស់លាស់។ របាយការណ៍នេះនឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រសួង ស្ថាប័ន និងគ.ជ.អ.ប. ក្នុងការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ខ. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកនៃជំហានទី៧នេះ គឺការរៀបចំបាននូវសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារ និងធនធានឡើងវិញរបស់ក្រសួង ស្ថាប័ន ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នសាមីពិនិត្យសម្រេច។

## គ. ដំណើរការ

ក្នុងជំហាននេះ ក្រុមការងារបច្ចេកទេសត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញតាមទម្រង់ដែលរួមមានចំនុចសំខាន់ៗដូចខាងក្រោម ៖

១. **សេចក្តីផ្តើម** ៖ សង្ខេបពីសាវតានៃកំណែទម្រង់នៃការអភិវឌ្ឍនតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អាណត្តិរបស់ក្រសួង ស្ថាប័ន និងជំហានដែលក្រសួង ស្ថាប័ននោះអនុវត្តក្នុងការពិនិត្យមើលមុខងារឡើងវិញ (ឧទាហរណ៍ ៖ ការបង្កើតក្រុមការងារបច្ចេកទេស ការរៀបចំបញ្ជីវិភាគមុខងារ)។

២. **ការពិពណ៌នាពីវិធីសាស្ត្រ និងជំហាននានា** ៖ រៀបរាប់អំពីវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងដំណើរការពិនិត្យមើលមុខងារឡើងវិញ ព្រមទាំងដំណើរការនៃការរៀបចំឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នផ្សេងៗ និងការចុះពិគ្រោះយោបល់ និងប្រមូលព័ត៌មាននៅមូលដ្ឋានជាដើម។

៣. **សំណើមុខងារ និងធនធាន និងជម្រើសនានាសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ៖** រៀបរាប់អំពី ចំនុចសំខាន់ៗដូចខាងក្រោម ដោយមានការគូសបញ្ជាក់អំពីហេតុផល និងសនិទានភាពច្បាស់លាស់ ៖

- មុខងារ និងឬមុខងាររងណាមួយដែលគួរផ្ទេរទៅឱ្យកម្រិតណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

- មុខងារ និងឬមុខងាររងណាមួយដែលគួរប្រគល់ ឬដែលគួរធ្វើប្រតិភូកម្ម
- មុខងារ និងឬមុខងាររងណាមួយដែលជាមុខងារជាកាតព្វកិច្ច ឬជាជម្រើស
- មុខងារណាខ្លះដែលគួរស្នើឱ្យអនុវត្តតាមវិធីសាស្ត្រខុសៗគ្នានៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតដូចគ្នា
- មុខងារណាខ្លះដែលគួរផ្ទេរក្នុងដំណាក់កាលដំបូង
- ធនធានចាំបាច់នានាដែលត្រូវផ្ទេរ (ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ពោលគឺធនធានដែលមានលក្ខណៈចាំបាច់បំផុតសម្រាប់អនុវត្តមុខងារដែលត្រូវផ្ទេរក្នុងដំណាក់កាលដំបូង
- ការយល់ឃើញ (ដោយផ្អែកលើការចុះមូលដ្ឋាន ) អំពីសមត្ថភាពជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារដែលត្រូវផ្ទេរ និងតម្រូវការសមត្ថភាពចាំបាច់នានាបន្ថែមទៀតដែលក្រសួង ស្ថាប័នត្រូវគាំទ្រ និងដោះស្រាយ ។

៤. **វិធីសាស្ត្រនៃការផ្ទេរក្នុងលក្ខណៈជាដំណាក់កាល និងក្នុងលក្ខណៈជាការផ្ទេរសាកល្បងនូវមុខងារណាមួយ :** រៀបរាប់អំពីសំណើ ឬជម្រើសនានាស្តីពីការផ្ទេរមុខងារជាដំណាក់កាល និងការផ្ទេរសាកល្បងឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានបញ្ជាក់ពីហេតុផល និងសនិទានភាពច្បាស់លាស់ ។

៥. **សេចក្តីសន្និដ្ឋាន :** សង្ខេបនូវសំណើ ឬជម្រើសសំខាន់ៗ និងបង្ហាញពីជំហានបន្តបន្ទាប់ទៀត ។

# ជំហានទី ៨
# ការរៀបចំការពិគ្រោះយោបល់ដើម្បីបញ្ចប់របាយការណ៍ ស្តីពីការពិនិត្យមើលមុខងារឡើងវិញ និងផ្ញើរបាយការណ៍ជូន គ.ជ.អ.ប.

## ក. គោលបំណង

គោលបំណងនៃជំហានទី៨នេះ គឺដើម្បីប្រមូល និងបញ្ចូលនូវធាតុចូលនានាដែលទទួលបានពីអ្នកពាក់ព័ន្ធសំខាន់ៗទៅក្នុងរបាយការណ៍ចុងក្រោយ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នពិនិត្យ និងឯកភាពមុននឹងបញ្ជូនមក គ.ជ.អ.ប. ពិនិត្យ និងសម្រេច។

## ខ. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកនៃជំហានទី៨នេះ គឺការសម្រេចបាននូវរបាយការណ៍ចុងក្រោយស្តីពីការពិនិត្យមើលមុខងារ និងធនធានឡើងវិញរបស់ក្រសួង ស្ថាប័ន ដែលត្រូវបានឯកភាពពីថ្នាក់ដឹកនាំក្រសួង ស្ថាប័នសាមី និងបញ្ជូនមក គ.ជ.អ.ប. ពិនិត្យ និងសម្រេច។

## គ. ដំណើរការ

ក្នុងការអនុវត្តជំហានទី៦នេះ ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័នមួយៗត្រូវអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម :

១. ក្រសួង ស្ថាប័នសាមីត្រូវរៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលធាតុចូលពីអ្នកពាក់ព័ន្ធនានាដើម្បីកែសម្រួល និងរៀបចំបញ្ចប់សេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារ និងធនធានឡើងវិញ។ សិក្ខាសាលាដែលរៀបចំឡើងនេះត្រូវបង្ហាញពីសេចក្តីព្រាងនៃសំណើ និងជម្រើសនានាដែលបានស្នើឡើងសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការគូសបញ្ជាក់អំពីហេតុផលដែលមាន សនិទានភាពច្បាស់លាស់។ ក្រសួង ស្ថាប័នត្រូវកំណត់ពីអ្នកពាក់ព័ន្ធដែលចាំបាច់ត្រូវចូលរួមក្នុងសិក្ខាសាលានេះ (សូមមើលឧបសម្ព័ន្ធ១)។

២. ក្រុមការងារបច្ចេកទេស ត្រូវធ្វើការកែសម្រួលបញ្ចប់នូវសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារ និងធនធានឡើងវិញឱ្យបានសមស្របដោយផ្អែកលើលទ្ធផលនៃសិក្ខាសាលា បន្ទាប់មកដាក់របាយការណ៍នេះជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ពិនិត្យ និងឯកភាព មុននឹងបញ្ជូនមក គ.ជ.អ.ប. ពិនិត្យ និងសម្រេច។

# ឧបសម្ព័ន្ធទី ១
# អ្នកពាក់ព័ន្ធនានាក្នុងដំណើរការពិនិត្យមើលមុខងារឡើងវិញ

**តួអង្គពាក់ព័ន្ធនានានៅក្នុងដំណើរការពិនិត្យមើលមុខងារឡើងវិញ គួរតែប្បីរួមមាន ៖**

- រដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរដ្ឋបាល)
- សមាគមក្រុមប្រឹក្សារដ្ឋបាលមូលដ្ឋាន
- ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពគ្រប់ថ្នាក់របស់ក្រសួង ស្ថាប័ន
- អតិថិជន និងក្រុមអ្នកប្រើប្រាស់សេវាដែលពាក់ព័ន្ធនឹងវិស័យនោះ
- សមាគមវិជ្ជាជីវៈដែលពាក់ព័ន្ធនឹងការផ្តល់សេវា
- សហគមន៍ និងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងវិស័យនោះ
- អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យនោះ
- វិស័យឯកជនដែលពាក់ព័ន្ធនឹងវិស័យនោះ
- ដៃគូអភិវឌ្ឍន៍ ឬអ្នកផ្តល់ជំនួយក្នុងវិស័យនោះ
- អ្នកសិក្សាស្រាវជ្រាវពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប. និង
- អ្នកពាក់ព័ន្ធផ្សេងទៀត។

ជារួម មានអ្នកពាក់ព័ន្ធសំខាន់ៗជាច្រើនដែលត្រូវបានពិគ្រោះយោបល់ជាមួយក្នុងអំឡុងដំណើរការពិនិត្យមើលមុខងារឡើងវិញ។ ប៉ុន្តែអ្វីដែលមានសារសំខាន់បំផុត គឺក្រុមការងារបច្ចេកទេសត្រូវស្វែងយល់អំពីទស្សនទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីមុខងារ និងធនធាន ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានជំនឿជឿជាក់ថាអាចគ្រប់គ្រង និងអនុវត្តបានដោយប្រសិទ្ធភាព។

ជាមួយគ្នានេះដែរ ការយល់ដឹងអំពីទស្សនទានរបស់មន្ទីរ អង្គភាពជំនាញនៃក្រសួង ស្ថាប័នសាមី និងក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត និងការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុក ខណ្ឌ គឺជាតុចូលដ៏មានសារសំខាន់ផងដែរ ដោយហេតុថា មុខងារមួយចំនួនរបស់អង្គភាពទាំងនោះអាចនឹងត្រូវបានផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ជម្រើសនានាដែលគួរពិចារណាសម្រាប់ធានាដល់ការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ :**

ក្រុមការងារបច្ចេកទេសអាចអញ្ជើញអ្នកពាក់ព័ន្ធសំខាន់ៗមួយចំនួនឱ្យចូលរួមគ្រប់ដំណើរការនៃការរៀបចំពិនិត្យមុខងារឡើងវិញ ។

ក្រុមការងារបច្ចេកទេសអាចអញ្ជើញអ្នកពាក់ព័ន្ធផ្សេងទៀត ឱ្យចូលរួមនៅការរៀបចំពិនិត្យមុខងារឡើងវិញតាមដំណាក់កាលណាមួយដូចខាងក្រោម :

- ការរៀបចំ និងឯកភាពលើផែនការការងារនៃការពិនិត្យមើលមុខងារឡើងវិញ
- ការកំណត់មុខងារនានាដែលត្រូវស្នើឡើងសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ការកំណត់នូវធនធាននានា ដែលត្រូវប្រើប្រាស់ដើម្បីអនុវត្តមុខងារដែលត្រូវបានស្នើឡើងសម្រាប់ការផ្ទេរ
- ការរៀបចំយុទ្ធសាស្ត្រសម្រាប់ការផ្ទេរមុខងារដែលត្រូវបានស្នើឡើង
- ការពិគ្រោះយោបល់ និងប្រមូលព័ត៌មាននៅថ្នាក់ក្រោមជាតិ
- ការរៀបចំសេចក្ដីព្រាងរបាយការណ៍ស្ដីពីការពិនិត្យមើលមុខងារឡើងវិញ
- ការរៀបចំការពិគ្រោះយោបល់ដើម្បីរៀបចំបញ្ចប់របាយការណ៍ស្ដីពីការពិនិត្យមើលមុខងារឡើងវិញនិង ផ្ញើរបាយការណ៍ជូន គ.ជ.អ.ប ។

# ឧបសម្ព័ន្ធទី២
# ការពិចារណាបន្ថែមដើម្បីកំណត់ពីកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការផ្ទេរមុខងារ

**លក្ខណៈវិនិច្ឆ័យដែលមានលក្ខណៈជាអន្តរជាតិសម្រាប់ការពិនិត្យមើលមុខងារឡើងវិញ :**

- **សេដ្ឋកិច្ចវិមាត្រ** : មានន័យថា ត្រូវពិចារណាទៅលើតម្លៃឯកតាសម្រាប់ការផ្តល់សេវាដែលមានលក្ខណៈទាបបំផុត (ឧទាហរណ៍ទី១ : ការទិញដុំនូវឱសថអាចនឹងចំណេញជាងការទិញរាយដោយរដ្ឋបាលថ្នាក់ក្រោមជាតិមួយៗ។ ឧទាហរណ៍ទី២ : ស្រុកមួយអាចចំណាយតិចទៅលើការជួលបុគ្គលិកម្នាក់សម្រាប់ផ្សព្វផ្សាយអំពីបច្ចេកទេសកសិកម្មដល់ឃុំទាំងអស់ក្នុងស្រុក ជាជាងការចំណាយច្រើនទៅលើការជួលបុគ្គលិកប្រភេទនេះសម្រាប់ឃុំនីមួយៗ ដែលនាំឱ្យបុគ្គលិកទាំងនេះមានពេលទំនេរច្រើន)។
- **ចំនួនប្រជាជនប្រៀបធៀបនឹងតំបន់ដែលទទួលផលប្រយោជន៍ពីសេវាកម្ម** : មានន័យថា ត្រូវពិចារណាថាតើចំនួនប្រជាជនប៉ុន្មានដែលសមស្របទៅនឹងការផ្តល់សេវាកម្មមួយ (ឧទាហរណ៍៖ សាលាបឋមសិក្សាមួយអាចដំណើរការទៅប្រកបដោយភាពស័ក្តិសិទ្ធិ និងមានប្រសិទ្ធភាពចំណាយ ប្រសិនបើមានចំនួនសិស្សដែលគ្រប់អាយុចូលរៀនជាអប្បបរមាចំនួន ... នាក់)។
- **តុល្យភាពរវាងចំណាយ និងផលប្រយោជន៍** : មានន័យថា ត្រូវពិចារណាទៅលើតុល្យភាពមួយដែលអាចទទួលយកបានរវាងផលប្រយោជន៍ជាអតិបរមាសម្រាប់ប្រជាពលរដ្ឋ ប្រៀបធៀបទៅនឹងការចំណាយ (ឧទាហរណ៍ : វាអាចនឹងចំណាយច្រើនក្នុងការផ្តល់សេវាកម្មមួយនៅថ្នាក់មូលដ្ឋាន ក៏ប៉ុន្តែការផ្តល់សេវាកម្មនេះអាចនឹងមានលក្ខណៈល្អប្រសើរជាង ក្នុងការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន)។
- **សមធម៌៖** មានន័យថា ត្រូវពិចារណាថាតើរដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតណាដែលអាចសម្រេចនូវលទ្ធផលរំពឹងទុកនានាប្រកបដោយសមធម៌ (ឧទាហរណ៍: តើយន្តការ និងការលើកទឹកចិត្តដែលមានប្រសិទ្ធភាពជាងគេបំផុតអាចបង្កើតបាននៅរដ្ឋបាលថ្នាក់ណា ដើម្បីធានាឱ្យមានការចូលរួម និងផលប្រយោជន៍ប្រកបដោយសមធម៌ក្នុងការផ្តល់សេវាសម្រាប់បុរស និងស្ត្រី ជនក្រីក្រ និងក្រុមងាយរងគ្រោះនានា)។
- **តម្រូវការឱ្យមានគណនេយ្យភាពខ្ពស់** : មានន័យថា តើរដ្ឋបាលថ្នាក់ណាដែលអាចអនុវត្តនូវមុខងារណាមួយប្រកបដោយគុណភាពដោយមាន**ការចូលរួម** និង**ការតាមដាន**របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ជាមួយគ្នានោះដែរ មុខងារនោះក៏តម្រូវឱ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋយ៉ាងខ្ពស់ផងដែរ (ឧទាហរណ៍ : សេវាផ្គត់ផ្គង់ទឹកស្អាតជាដើម)។

- **ចំណង់ចំណូលចិត្តមូលដ្ឋាន** : មានន័យថា តើចំណង់ចំណូលចិត្តរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានអាចដូច ឬខុសគ្នាពីដែនសមត្ថកិច្ចមួយទៅដែនសមត្ថកិច្ចមួយដែរឬទេ? (ឧទាហរណ៍ : ដែនសមត្ថកិច្ចមួយដែលមានជនជាតិដើមភាគតិចចំនួនច្រើនលើសលុបអាចមានចំណងចំណូលចិត្តផ្សេងគ្នាពីចំណង់ចំណូលចិត្តរបស់ដែនសមត្ថកិច្ចនានាជាទូទៅ) ។
- **លក្ខខណ្ឌនានាក្នុងមូលដ្ឋាន** : មានន័យថា តើលក្ខខណ្ឌនានារបស់មូលដ្ឋានទីមួយៗអាចដូចគ្នា ឬខុសគ្នាពីដែនសមត្ថកិច្ចមួយទៅដែនសមត្ថកិច្ចមួយទៀតដែរឬទេ (ឧទាហរណ៍ : ដែនសមត្ថកិច្ចមួយអាចមានតម្រូវការផ្សេងក្នុងការបញ្ចៀសគ្រោះមហន្តរាយ ដោយផ្អែកតាមលក្ខណៈជាក់ស្តែងនៃទីតាំងភូមិសាស្ត្ររបស់មូលដ្ឋាននោះ) ។
- **ភាពហួសព្រំដែនសមត្ថកិច្ច** : មានន័យថា តើផលប្រយោជន៍ ការចំណាយ និងផលវិបាកជាអវិជ្ជមានណាមួយដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារ ត្រូវបានកំហិតចំពោះដែនសមត្ថកិច្ចរបស់រដ្ឋបាលណាមួយដែរឬទេ? (ឧទាហរណ៍ : ការសាងសង់ទំនប់ទឹកមួយអាចធ្វើឱ្យលិចលង់ដល់ដែនសមត្ថកិច្ចរបស់រដ្ឋបាលជិតខាង) ។
- **មុខងារជាប្រពៃណីនៅមូលដ្ឋាន** : មានន័យថា តើមុខងារមួយមានភាពផ្សារភ្ជាប់ទៅនឹងប្រពៃណីរបស់រដ្ឋបាលមូលដ្ឋានដែរឬទេ (ឧទាហរណ៍ : ការដោះស្រាយវិវាទក្នុងមូលដ្ឋាន) ។
- **ព័ត៌មានមូលដ្ឋាន** : មានន័យថា តើព័ត៌មានមូលដ្ឋានត្រូវការចាំបាច់សម្រាប់ការអនុវត្តមុខងារដែរឬទេ? (ឧទាហរណ៍ : ការតាមដានវត្តមានរបស់គ្រូបង្រៀនប្រចាំថ្ងៃ) ។
- **ការសម្របសម្រួលក្នុងមូលដ្ឋាន** : មានន័យថា តើការអនុវត្តមុខងារទាមទារនូវការសម្របសម្រួលនិងឬការកៀរគរធនធាននានានៅក្នុងមូលដ្ឋាននោះដែរឬទេ (ឧទាហរណ៍ :ការសាងសង់ប្រព័ន្ធលូបង្ហូរទឹក) ។
- **កិច្ចសហការជាអន្តរដែនសមត្ថកិច្ច** : មានន័យថា តើអាចមានសក្តានុពលដែលឬទេ ប្រសិនបើមានកិច្ចសហការរវាងរដ្ឋបាលជាច្រើនក្នុងការផ្តល់នូវសេវាកម្មមួយ ក្នុងពេលដែលសក្តានុពលនោះពុំអាចបង្កើតបានដោយរដ្ឋបាលទោលណាមួយ (ឧទាហរណ៍ : ឃុំពីរសហការគ្នាក្នុងការកសាងលូបង្ហូរទឹកដែលឆ្លងកាត់ឃុំទាំងពីរ) ។
- **ការសម្របសម្រួលតាមវិស័យ** : មានន័យថា តើការសម្របសម្រួលអន្តរវិស័យមានភាពចាំបាច់ដែរឬទេ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងអនុវត្តមុខងារនោះ? (ឧទាហរណ៍ : ការរៀបចំផែនការប្រើប្រាស់ដីធ្លី) ។

**ចំណុចសំខាន់ៗមួយចំនួនផ្សេងទៀតសម្រាប់ក្រសួង ស្ថាប័នទាំងឡាយដែលអង្គភាពនៅមូលដ្ឋានរបស់ខ្លួនមានព្រំដែនសមត្ថកិច្ចមិនស៊ីគ្នាជាមួយនឹងព្រំដែនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍៖ ស្រុកប្រតិបត្តិរបស់វិស័យសុខាភិបាល)**

ជារួម ក្រសួង ស្ថាប័នទាំងនេះដែលមានបំណងផ្ទេរមុខងារទៅឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អាចមានជម្រើសមួយចំនួនដូចខាងក្រោម ៖

- ការរៀបចំកែសម្រួលអង្គភាពនៅមូលដ្ឋានរបស់ខ្លួនឱ្យស៊ីគ្នាជាមួយព្រំដែនរបស់ស្រុក ក្រុង ឬឃុំ សង្កាត់តាមលទ្ធភាពដែលអាចធ្វើទៅបាន ។
- ប្រសិនបើគ្មានលទ្ធភាពរៀបចំឡើងវិញនូវអង្គភាពរបស់ខ្លួនឡើងវិញ ក្រសួង ស្ថាប័នទាំងនោះគួរគប្បីពិចារណាទៅលើ ៖
  - ការផ្ទេរមុខងារទៅឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតសមស្រប (ឧទាហរណ៍ : មុខងារមួយដែលផ្តល់ប្រយោជន៍ដល់ឃុំពីរ ឬច្រើន គួរតែត្រូវបានផ្ទេរទៅរដ្ឋបាលស្រុក ដោយឡែកមុខងារដែលផ្តល់ប្រយោជន៍ដល់ស្រុកពីរ ឬច្រើន គួរតែត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលខេត្ត) ។
  - ការផ្ទេរមុខងារណាមួយឱ្យទៅដល់រដ្ឋបាលពីរ ឬច្រើន ដែលត្រូវរួមចំណែកធនធានជាមួយគ្នារវាងរដ្ឋបាលទាំងនោះក្នុងការគ្រប់គ្រង និងអនុវត្តមុខងារនោះ (មាត្រា២៣៦នៃច្បាប់រៀបចំអង្គការ) ។ ចំពោះមុខងារដែលត្រូវបានផ្ទេរទៅឱ្យដល់រដ្ឋបាលពីរ ឬច្រើនសម្រាប់អនុវត្តរួមគ្នា គួរគប្បីត្រូវពិចារណាទៅលើការបង្កើតនូវរចនាសម្ព័ន្ធសម្របសម្រួល និងអង្គនីតិបុគ្គលជាផ្លូវការមួយសម្រាប់ការអនុវត្តនូវមុខងាររួមគ្នានោះឱ្យបានសមស្រប ។